# មេរៀនទី៤
# មនុស្ស អង្គការ និងការគ្រប់គ្រង

## People, Organization and Management



# មេរៀន ៤.១
# ការគ្រប់គ្រងខ្លួនឯង និងការគ្រប់គ្រងអ្នកដទៃ

## ខ្លឹមសារគន្លឹះ

មនុស្សគឺជាធនធានសំខាន់បំផុតសំរាប់ការធ្វើអាជីវកម្ម ឬសំរាប់អង្គការ។ មនុស្សគ្រប់គ្រង និងរៀបចំទៅតាមរចនាបថនៃការគ្រប់គ្រង និងបទពិសោធន៍ផ្សេងៗរបស់ពួកគេ។ មានស្ត្រីជាច្រើនគឺជាអ្នកគ្រប់គ្រងអាជីវកម្មដ៏ពូកែ។ ទោះបីយ៉ាងណាក៏ដោយ ជំនាញ និងសមត្ថភាពពិសេសរបស់ពួកគេ ដែលជាអ្នកគ្រប់គ្រង ជារឿយៗ តែងតែយកមកប្រើបានតិចតួចនៅឡើយ ហើយកម្មវិត្ថុរបស់អង្គការ និងអ្នកគ្រប់គ្រង ជាញឹកញយតែងតែមិនត្រូវបានគេយកចិត្តទុកដាក់ នៅក្នុងកម្មវិធីបណ្តុះបណ្តាលសំរាប់ស្ត្រីជាសហគ្រិនដែលមានកំរិតអប់រំទាប ដោយសន្មតថា ស្ត្រីទាំងនោះពុំចាំបាច់មានជំនាញខាងការគ្រប់គ្រងទេ។

## គោលដៅ

មេរៀន ៤.១នេះ មានគោលបំណងដើម្បីបង្កើនការយល់ដឹង និងអោយមានការទុកចិត្តលើខ្លួនឯងរបស់ស្ត្រីជាសហគ្រិន ដើម្បីដើរតួជាអ្នកគ្រប់គ្រង និងជាអ្នកដឹកនាំនៅក្នុងសហគ្រាស និងដើម្បីប្រើប្រាស់ធនធាន ជំនាញ និងកំលាំងចិត្តរបស់ខ្លួនផ្ទាល់ និងរបស់បុគ្គលិកអោយអស់លទ្ធភាពនៅក្នុងអាជីវកម្មរបស់ពួកគេ។

## លំហាត់

២៤. ការគ្រប់គ្រងខ្លួនឯង និងអ្នកដទៃ
២៥. ការគ្រប់គ្រងបុគ្គល គ្រួសារ ឬក្រុមអាជីវកម្ម
២៦. អាជីវកម្មគ្រួសារ : ការចែករំលែកការងារ ការសំរេចចិត្ត និងការរកប្រាក់ចំណូល
២៧. ដំណើរដែលទុកចិត្ត (The Trust Walk) (ជំរើស)

# លំហាត់ទី២៤ : ការគ្រប់គ្រងខ្លួនឯង និងការគ្រប់គ្រងក្រុមការងារ

## គោលដៅ

- ដើម្បីជួយស្ត្រីជាសហគ្រិនអោយមានទំនុកចិត្តលើខ្លួនឯងនៅក្នុងការគ្រប់គ្រងសហគ្រាសរបស់គាត់
- ដើម្បីជួយសិក្ខាកាមអោយបានដឹងអំពីការជ្រើសរើសរចនាបថនៃភាពជាអ្នកដឹកនាំ

## រយៈពេល: ៩០នាទី

## ការរៀបចំបន្ទប់រៀន

- រៀបចំកន្លែងអង្គុយជារាងអក្សរ U សំរាប់ក្រុមធំ
- រឺងក្រុមតូចអង្គុយលើកៅអី ឬអង្គុយផ្ទាល់ដី

## សំភារៈ និងការត្រៀមរៀបចំ

- ក្រដាសផ្ទាំងធំ និងក្តារខៀន
- ក្រដាសកាសែត ក្រដាសផ្ទាំងធំ ក្រដាសកាតុង ទស្សនាវដ្តី ពែងក្រដាស ប្រអប់ក្រដាស សំភារៈតុបតែងផ្សេងៗ ដែលមាននៅក្នុងបន្ទប់រៀន កន្ត្រៃ អំបោះ ឬខ្សែ ស្កុតក្រដាស ឬប្រដាប់សំរាប់បិទផ្សេងៗ: មួយក្រុមទទួលបានសំភារៈទាំងនេះមួយកំភ្លេ។
- ត្រៀមបែបបទវាយតំលៃសំរាប់ការគ្រប់គ្រងសំណង់អាគារ នៅលើក្រដាសផ្ទាំងធំ ឬក្តារខៀន។

## ច្រើ សន្លឹកផ្លាស្ទីក Transparency ឬក្រដាសផ្ទាំងធំ

- រចនាបថនៃការគ្រប់គ្រង
- បែបបទវាយតំលៃសំរាប់ការគ្រប់គ្រងសំណង់អាគារ

## ទំនាក់ទំនងវគ្គសិក្សា

- មេរៀន១.២: វដ្តជីវិតរបស់មនុស្ស និងសហគ្រាស លំហាត់ទី៤
- មេរៀន២.១: ស្ត្រីជាអាជីវករ : គាត់អាចធ្វើបាន លំហាត់ទី៥

## ម្លង់វគ្គសិក្សា

### ជំហានទី១ - ៥នាទី

ជារឿយៗ ស្ត្រីគឺជាអ្នកគ្រប់គ្រងដ៏ពូកែ។ គាត់អាចធ្វើការងារជាច្រើនក្នុងពេលតែមួយ។ សុំអោយសិក្ខាកាមរៀបរាប់ពីករណីកិច្ច និងកាតព្វកិច្ចដែលពួកគេតែងតែចាត់ចែងធ្វើកំឡុងពេល១ថ្ងៃ ដោយគិតចាប់ពីពេលភ្ញាក់ពីដំណេកពេលព្រឹក រហូតដល់ពេលចូលដំណេកវិញនៅពេលយប់ (១២ ម៉ោង) គិតទាំងការងារផ្ទះសំបែង និងសកម្មភាពរកប្រាក់ចំណូលនៅខាងក្រៅ។ ចូរកត់ត្រារាល់ឧទាហរណ៍ អំពីករណីកិច្ចដែលពួកគេបានលើកឡើងនៅលើក្រដាសផ្ទាំងធំ។

បន្តធ្វើទៀត ដោយលើកជាសំនួរថា តើគោលបំណងនិងលទ្ធផលបែបណាដែលគេចង់ធ្វើអោយបានសំរេចនៅក្នុងជីវិត និងអាជីវកម្មរបស់គេ។ ពាក្យគន្លឹះសំខាន់ៗ ដែលត្រូវលើកឡើង ដូចជា ប្រាក់ចំណូលបន្ថែម គ្រួសារមានសុភមង្គល ធ្វើការងារដែលមានប្រយោជន៍ ការមានទំនាក់ទំនងល្អ ឬការចូលរួមវិភាគទាននៅក្នុងសហគមន៍។ សរសេរពាក្យទាំងនេះនៅលើក្រដាសផ្ទាំងធំ។

### ជំហានទី២ - ១៥នាទី

សុំអោយសិក្ខាកាមរៀបរាប់ពីជំនាញសំខាន់ៗដែលគេត្រូវការ ដើម្បីក្លាយជាអ្នកគ្រប់គ្រងដ៏ពូកែ។ ចូររៀបរាប់ដោយកត់ត្រាលើក្រដាសផ្ទាំងធំ។ សិក្ខាកាមទំនងជាត្រូវលើកបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងគោលបំណង និងទិន្នផល (ឈានដល់គោលដៅ ឬលទ្ធផល) ទំនាក់ទំនង (ពូកែទាក់ទង) និងតំលៃ (ភាពសុច្ចរិត និងសាមគ្គីភាព)។ បូកសរុបការពិភាក្សា ដោយផ្អែកលើបញ្ជីជំនាញគ្រប់គ្រងសំខាន់ៗ។ ក្នុងនាមជាអ្នកគ្រប់គ្រង អ្នកចាំបាច់ត្រូវ :

- មានគំនិតផ្តួចផ្តើម
- កំណត់គោលបំណង និងទស្សនៈវិស័យ
- រៀបចំផែនការអោយមានលក្ខណៈជាប្រព័ន្ធ ដើម្បីឈានទៅសំរេចគោលបំណង
- មានលក្ខណៈមោះមុតលើការសំរេចលទ្ធផល ដើម្បីឈានដល់គោលបំណង
- មានលក្ខណៈជាក់ស្តែងអំពីរឿងរ៉ាវទាំងឡាយ និងធ្វើវាអោយបានសំរេច
- កំណត់គោលបំណងអោយមានលក្ខណៈជាប្រព័ន្ធ
- គិតគូរពីភាពប្រថុយប្រថានៈ ធ្វើការប្រមូលព័តិមាន និងជ្រើសរើសវិធីល្អបំផុត ដើម្បីអាចចាប់យកឱកាស និងដែលមានលក្ខណៈបត់បែន
- បង្កលក្ខណៈអោយអ្នកដទៃបានចូលរួមសំរេចការងារៈ សហប្រតិបត្តិការ ការសំរបសំរួល ការប្រគល់ ភារកិច្ច និងការទុកចិត្ត
- ត្រូវមានភាពសុចរិត និងមានការទទួលខុសត្រូវ
- បង្កើតសាមគ្គីភាពរវាងក្រុមផ្សេងៗ និងបង្កើតអោយមានការចាប់អារម្មណ៍ក្នុងអាជីវកម្ម : ក្រុមគ្រួសារ សហគមន៍ និងសង្គម
- ជំនាញផ្សេងៗទៀតដែលបានរៀបចំជាបញ្ជី

សួរទៅសិក្ខាកាម ប្រសិនបើគេឃើញមានភាពខុសគ្នាណាមួយទៀតនៅក្នុងលំនាំ និងរចនាបថនៃការគ្រប់គ្រងរបស់ស្ត្រី និងបុរស ដោយប្រើបញ្ជីរៀបរាប់ខាងលើ។ បុគ្គលិកលក្ខណៈយេនឌ័ររួមនឹងកើតមានឡើង ដូចជា : បុរសពូកែក្នុងការដឹកនាំ ការកំណត់គោលបំណង និងការហ៊ានប្រថុយប្រថាន។ រីឯស្ត្រីវិញ ពូកែនៅក្នុងការសហការ ការទំនាក់ទំនង ការថែទាំ ការទទួលខុសត្រូវ និងការស្មោះត្រង់។ ចូរពន្យល់ ដូចតទៅ :

- បុគ្គលិកលក្ខណៈយេនឌ័រទាំងនេះ ជាប់ទាក់ទងទៅនឹងតំលៃសង្គម ដែលថាតើស្ត្រី និងបុរសពូកែធ្វើអ្វីខ្លះនៅក្នុងសង្គមរបស់ពួកគេ។ ចំនែកឯក្មេងស្រី និងក្មេងប្រុសមានការរស់នៅក្នុងសង្គម ទទួលការចិញ្ចឹម និងការអប់រំ និងធំធាត់សមស្របទៅតាមសង្គមនោះ។

- ការគ្រប់គ្រងល្អទាមទារអោយមានការផ្សំបញ្ចូលគ្នានូវអ្វីដែលបានរៀបរាប់ខាងលើ គឺបុគ្គលិកលក្ខណៈរបស់ស្ត្រី និងរបស់បុរស ដែលសឹងតែគ្រប់អ្នកគ្រប់គ្រងទាំងអស់ត្រូវមាន ។
- ហេតុដូចនេះ ជារឿយៗ បុរស និងស្ត្រីត្រូវការការកសាងសមត្ថភាពផ្នែកជំនាញដែលពួកគេខ្វះខាត ដើម្បីអោយពួកគេក្លាយជាអ្នកគ្រប់គ្រងពូកែ ។
- សុំអោយសិក្ខាកាមរៀបរាប់ពីចំនុចខ្លាំងនៃជំនាញគ្រប់គ្រងរបស់ខ្លួនគេ និងវិស័យដែលគេចង់ធ្វើអោយរីកចំរើន ។ លើកទឹកចិត្តអោយសិក្ខាកាមផ្តោតទៅលើចំនុចខ្លាំងដែលគេបានប្រើ ហើយកុំនិយាយច្រើនពេកពីចំនុចខ្សោយដែលគេត្រូវជំនះនោះ ។

## ជំហានទី៣ - ១០នាទី

ណែនាំពីរចនាបថនៃការគ្រប់គ្រងផ្សេងគ្នា ដែលគេជួបប្រទះជាធម្មតា នៅក្នុងប្រភេទផ្សេងៗនៃសហគ្រាសក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ :

### រចនាបថនៃការគ្រប់គ្រង

| | |
|---|---|
| រចនាបថនៃការគ្រប់គ្រងបែបបុរាណ/ឋានានុក្រម | យកចិត្តទុកដាក់ទៅលើការធ្វើអោយបានសំរេចគោលដៅ ទោះបីជាមានអ្វីកើតឡើងក៏ដោយ ។ អ្នកដឹកនាំត្រូវធ្វើសេចក្តីសំរេចចិត្តតាមឋានានុក្រម ហើយដាក់អោយធ្វើតាមវិធីសាស្ត្ររបស់ថ្នាក់លើ ។ |
| រចនាបថនៃការគ្រប់គ្រងបែបបច្ចេកវិទ្យា និងរោងចក្រ | យកចិត្តទុកដាក់ទៅលើផលិតភាព និងទិន្នផល មិនសូវយកចិត្តទុកដាក់ទៅលើមនុស្សទេ ។ |
| រចនាបថនៃការគ្រប់គ្រងដែលផ្តោតសំខាន់ទៅលើមនុស្ស | យកចិត្តទុកដាក់ទៅលើការលើកទឹកចិត្តមនុស្សការងារជាក្រុម និងបង្កលក្ខណៈអោយក្រុមធ្វើសេចក្តីសំរេចចិត្ត ។ |
| រចនាបថនៃការគ្រប់គ្រងបែបសង្គម | យកចិត្តទុកដាក់ទៅលើសមត្ថភាពសង្គម ដំណើរការការប្រាស្រ័យទាក់ទង និងការតំរង់ទៅរកសេវាកម្ម ។ |

ចូរពន្យល់ប្រាប់ថាការផ្សំបញ្ចូលគ្នានូវរចនាបថនៃការគ្រប់គ្រងខាងលើ គឺជាវិធីដ៏ល្អបំផុតនៅក្នុងការអនុវត្តន៍។ រចនាបថនៃការគ្រប់គ្រងបែបបុរាណឬឋានានុក្រម និងរចនាបថគ្រប់គ្រងបែបបច្ចេកវិទ្យានិងរោងចក្រ គឺមានលក្ខណៈចរិតជាវិធីសាស្ត្រ ‘ពីលើមកក្រោម’។ ផ្ទុយទៅវិញ រចនាបថនៃការគ្រប់គ្រងបែបសង្គម និងបែបផ្តោតសារៈសំខាន់ទៅលើមនុស្ស គឺមានលក្ខណៈចរិតជាវិធីសាស្ត្រ ‘ពីក្រោមទៅលើ’។ គេត្រូវការវិធីសាស្ត្រទាំងពីរនេះ ដើម្បីសំរេចការងារអោយបាន។

**ជំហានទី៤** - ៣០នាទី

បែងចែកសិក្ខាកាមជាក្រុមតូចៗដែលមានគ្នាពី៥ទៅ៦នាក់ក្នុងមួយក្រុម។ ចូរពន្យល់ប្រាប់ថាពួកគេនឹងមានឱកាសធ្វើការសាកល្បងជំនាញគ្រប់គ្រង និងជំនាញដឹកនាំរបស់គេផ្ទាល់នៅក្នុងក្រុម។ ពួកគេនឹងត្រូវធ្វើការរួមគ្នាក្នុងការកសាងអាគារក្រដាសមួយ ជាមួយនឹងសំភារៈដែលបានចែកជូន។ គុណភាពរបស់អាគារដែលគេសង់នោះ ត្រូវបានគេវិនិច្ឆ័យដោយផ្អែកលើលក្ខណៈវិនិច្ឆ័យបី :

- កំពស់ : អាគារកាន់តែខ្ពស់ កាន់តែល្អ
- ភាពរឹងមាំ : អាគារកាន់តែរឹងមាំ កាន់តែល្អ
- ភាពច្នៃប្រឌិត : តើផលិតផលចុងក្រោយនេះ មានភាពច្នៃប្រឌិតបែបណា?

ចូរប្រាប់អោយក្រុមនីមួយៗធ្វើការជ្រើសរើសមេដឹកនាំក្រុម ដែលជាអ្នកទទួលខុសត្រូវការងាររបស់ក្រុម។ ក្រុមនីមួយៗមានពេល២០នាទី ក្នុងការកសាងអាគារនេះ។ សូមចែកសំភារៈសាងសង់ និងអោយសញ្ញា **ចាប់ផ្តើម**។

## ជំហានទី៥ - ៣០នាទី

សុំអោយក្រុមទាំងអស់បញ្ឈប់ភ្លាមនៅពេលដល់ម៉ោង។ ក្រុមអ្នកបណ្តុះបណ្តាលធ្វើការវាយតំលៃជាលើកដំបូង និងកំណត់ពីចំនុចខ្លាំង និងចំនុចខ្សោយរបស់អាគារនីមួយៗ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានជ្រើសរើសខាងលើ។

ពិនិត្យមើលលំហាត់ឡើងវិញដោយសួរសិក្ខាកាមនូវសំនួរ ដូចតទៅ ៖

- តើអ្នកពេញចិត្តនឹងលទ្ធផលអាគារក្រដាសរបស់ក្រុមអ្នក ដែរឬទេ?
- តើអ្នកគិតយ៉ាងណាអំពីភារៈកិច្ចដែលបានចាត់ចែងនៅក្នុងក្រុម នៅពេលកំពុងសាងសង់អាគារ?
- តើមានកត្តាជំនួយ និងកត្តារារាំងអ្វីខ្លះ នៅក្នុងការសំរេចគោលបំណងរបស់អ្នក?
- តើអ្នកអាចនិយាយយ៉ាងណាអំពីតួនាទីរបស់ប្រធានក្រុម និងសមាជិកក្រុម កំឡុងពេលដំណើរការកសាងអាគារនោះ? តើអ្នកពេញចិត្តរចនាបថគ្រប់គ្រងរបស់គាត់ និងក្រុមការងារ ដែរឬទេ? ហេតុអ្វី បានជាពេញចិត្ត? ឬហេតុអ្វីបានជាមិនពេញចិត្ត?

ចូរបំពេញមតិយោបល់នៅក្នុងបែបបទត្រួតពិនិត្យ (ជំនួយការបណ្តុះបណ្តាលទី៧៤) នៅលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ ដើម្បីកត់ត្រាទស្សនៈរបស់សិក្ខាកាម។ ជំហាននេះត្រូវធ្វើអោយបានល្អដោយក្រុមអ្នកបណ្តុះបណ្តាលពីរនាក់៖ ម្នាក់ដឹកនាំការពិភាក្សា រីឯម្នាក់ទៀតជាអ្នកបំពេញទំរង់បែបបទ។

សុំអោយសិក្ខាកាមទាំងអស់ជ្រើសរើស ‘អាគារដែលឈ្នះ’ មួយ (ឬច្រើន)។ ចូរពិភាក្សាដោយប្រើពាក្យ ហេតុអ្វី អ្វី និងដោយវិធីណាអំពីរចនាបថគ្រប់គ្រងដែលប្រើនៅក្នុងក្រុមកំឡុងពេលសាងសង់ (ជំហានទី៤) និងសុំអោយសិក្ខាកាមពន្យល់ពីរបៀបដែលគេគ្រប់គ្រងការងារ នៅក្នុងក្រុមរបស់គេ។ ឧទាហរណ៍៖

- សំនួរសំរាប់សមាជិកក្រុម៖ តើអ្នករាល់គ្នាបានធ្វើដូចគ្នា ឬក៏មានការបែងចែកភារកិច្ចគ្នាធ្វើ។ តើប្រធានក្រុមមានតួនាទីធ្វើអ្វីខ្លះ? តើគាត់បានធ្វើការងារដូចសមាជិកដទៃទៀតធ្វើដែរឬទេ?

តើបានធ្វើការងារអ្វីផ្សេងទៀត ដែរឬទេ? តើគ្រាន់តែត្រួតត្រាប៉ុណ្ណោះឬ? តើសមាជិកក្រុមដទៃទៀត ជួយណែនាំអ្នកផ្សេងដែរឬទេ?

- សំនួរសំរាប់ប្រធានក្រុម ដើម្បីពន្យល់អំពីការគ្រប់គ្រងក្នុងក្រុមរបស់គេ និងរចនាបថនៃភាពជាអ្នកដឹកនាំ។ តើអ្នកបានបែងចែកភារកិច្ចទៅសមាជិកក្រុមផ្សេងធ្វើដែរឬទេ? តើអ្នកមានបានចូលប្រឡូកធ្វើអាគារដែរឬទេ ឬមួយក៏អ្នកគ្រាន់តែត្រួតត្រា និងពិនិត្យមើលដំណើរការទាំងមូល? តើពួកគេបានធ្វើតាមអ្វីដែលអ្នកប្រាប់គេដែរឬទេ? តើពួកគេបានធ្វើអ្វីមួយដោយឥតព្រៀងទុក ដែរឬទេ? តើអ្នកប្រាកដថា គ្រប់ៗគ្នាបានប្រឹងប្រែងធ្វើការអស់ពីដៃពីជើង ដែរឬទេ?

សុំអោយសិក្ខាកាមឆ្លុះបញ្ចាំងមើលថា តើក្រុមការងារ និងភាពជាអ្នកដឹកនាំនៅក្នុងក្រុមឈ្នះបានចូលរួមវិភាគទានចំពោះភាពជោគជ័យរបស់គេដែរ ឬអត់?

បញ្ជាក់អោយបានច្បាស់លាស់នូវចំនុចរៀនសូត្រទាំងឡាយដែលបង្ហាញពី ‘ក្បួនសំរាប់ភាពជោគជ័យ’ ក្នុងការគ្រប់គ្រង។ ឧទាហរណ៍ ការផ្តោតទៅលើការបែងចែកភារកិច្ច ដើម្បីឈានទៅដល់គោលដៅ ការសំដែងលេងជាក្រុម ការចែករំលែកការងារ ការបែងចែកការងារតាមភារកិច្ច ប្រើភាពខ្លាំងរបស់បុគ្គលម្នាក់ៗ ការចូលរួមវិភាគទានចំពោះភាពជោគជ័យរបស់ក្រុមទាំងមូល ការត្រួតពិនិត្យចលនាការងារ និងការប្តេជ្ញាធ្វើតាមកិច្ចសន្យាដែលបានបង្ហាញដោយក្រុមការងារ ។ល។

សន្និដ្ឋានវគ្គទាំងមូល ដោយសង្កត់បញ្ជាក់លើចំនុច ដូចតទៅ ៖

- ការគ្រប់គ្រងល្អគឺជាការចាំបាច់ ដើម្បីឈានទៅសំរេចគោលបំណងនៅក្នុងជីវិតរបស់គេ (ដូចដែលបានលើកឡើងដោយសិក្ខាកាមកំឡុងជំហានទី១)។

- ការគ្រប់គ្រងល្អលើខ្លួនឯង និងលើអ្នកដទៃ មិនមែនជាកិច្ចការរបស់អ្នកដឹកនាំតែម្នាក់ឯងឡើយ ។ វាជាភារកិច្ចរបស់អ្នកទាំងអស់គ្នា ។ អ្នកដឹកនាំល្អត្រូវមានជំនាញគ្រប់គ្រង ឆ្លាតវៃ ។
- ការទទួលខុសត្រូវរបស់សមាជិកក្រុម និងភាពជាអ្នកដឹកនាំល្អទាំងអស់ គឺជាកត្តាសំខាន់សំរាប់ភាពជោគជ័យរបស់ក្រុមការងារ និងការឈានទៅសំរេចគោលបំណង ។
- សំនួរមិនត្រូវអនុម័តថារចនាបថនៃការគ្រប់គ្រងមួយណាត្រូវ មួយណាខុសឡើយ តែគេត្រូវធ្វើការស្វែងយល់ និងពិចារណាគ្រប់រចនាបថនៃការគ្រប់គ្រងទាំងអស់ ដើម្បីអោយសមស្របទៅនឹងបុគ្គលិកលក្ខណៈរបស់អ្នក និងអាជីវកម្មជាលក្ខណៈបុគ្គលក្តី ឬជាក្រុមប្រតិបត្តិការក្តី ។

ជំនួយការបណ្តុះបណ្តាលទី៧៣

# របៀបនៃការគ្រប់គ្រង

## Management Styles

| | |
|---|---|
| របៀបនៃការគ្រប់គ្រងបែបបុរាណ/ឋានានុក្រម | យកចិត្តទុកដាក់ទៅលើការធ្វើអោយបានសំរេចគោលដៅ ទោះបីជាមានអ្វីកើតឡើងក៏ដោយ ។ អ្នកដឹកនាំត្រូវធ្វើសេចក្តីសំរេចចិត្តតាមឋានានុក្រម ហើយដាក់អោយធ្វើតាមវិធីសាស្ត្ររបស់ថ្នាក់លើ ។ |
| របៀបនៃការគ្រប់គ្រងបែបបច្ចេកវិទ្យា និងរោងចក្រ | យកចិត្តទុកដាក់ទៅលើផលិតភាព និងទិន្នផល មិនសូវយកចិត្តទុកដាក់ទៅលើមនុស្សទេ ។ |
| របៀបនៃការគ្រប់គ្រងដែលផ្តោតសំខាន់ទៅលើមនុស្ស | យកចិត្តទុកដាក់ទៅលើការលើកទឹកចិត្ត មនុស្ស ការងារជាក្រុម និងបង្កលក្ខណៈអោយក្រុមធ្វើសេចក្តីសំរេចចិត្ត ។ |
| របៀបនៃការគ្រប់គ្រងបែបសង្គម | យកចិត្តទុកដាក់ទៅលើសមត្ថភាពសង្គម ដំណើរការ ការប្រាស្រ័យទាក់ទង និងការតំរង់ទៅរកសេវាកម្ម ។ |

ជំនួយការបណ្តុះបណ្តាលទី៧៤

# បែបបទត្រួតពិនិត្យសំរាប់ការគ្រប់គ្រងសំណង់អាគារ

## Review Form for Tower Building Management

| ក្រុម | ការពេញចិត្តដំណើរការ និងទិន្នផល? | កត្តាជំនួយ | កត្តារារាំង | ការគ្រប់គ្រងនៅក្នុងក្រុម: តួនាទីរបស់អ្នកដឹកនាំ និងសមាជិក |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |

## លំហាត់ទី២៥: ការគ្រប់គ្រងបុគ្គល គ្រួសារ ឬក្រុមអាជីវកម្ម

### គោលដៅ

- ដើម្បីជួយសិក្ខាកាមអោយចេះរិះគិត និងសំរេចចិត្តអំពីតួនាទីរបស់គេ ដែលជាម្ចាស់អាជីវកម្ម ឬជាសមាជិកគ្រួសារ ឬក្រុមអាជីវកម្ម។
- ដើម្បីធ្វើអោយប្រសើរឡើងនូវការចាត់តាំង និងការគ្រប់គ្រងបុគ្គល គ្រួសារ ឬក្រុមអាជីវកម្ម។

### រយៈពេល: ៦០នាទី

### ការរៀបចំបន្ទប់រៀន: រៀបចំកន្លែងអង្គុយជារាងអក្សរ U

### សំភារៈ និងការត្រៀមរៀបចំ

- ក្រដាសផ្ទាំងធំ និងក្រដាសតូចដែលមាន៤ពណ៌ សិក្ខាកាមម្នាក់ៗទទួលបានពី១ទៅ៣ពណ៌។
- សរសេរតារាងម៉ាទ្រីកផែនការសកម្មភាពកត្តាជំនួយ និងកត្តារារាំង នៅលើក្រដាសផ្ទាំងធំ ហើយ ចែកអោយក្រុមនីមួយៗ មួយក្រុមមួយផ្ទាំង។

**ប្រើ** សន្លឹកផ្លាស្ទិក Transparency ឬក្រដាសផ្ទាំងធំ

តារាងម៉ាទ្រីកផែនការសកម្មភាពកត្តាជំនួយ និងកត្តារារាំង។

### ទំនាក់ទំនងទៅវគ្គសិក្សា

- មេរៀន ២.១: ស្ត្រីអាជីវករ : គាត់អាចធ្វើបាន លំហាត់ទី៧
- មេរៀន ៤.៣: ការធ្វើផែនការសកម្មភាពសំរាប់អាជីវកម្មរបស់អ្នក លំហាត់ទី៣១ ស្តីពី ការធ្វើផែនការអាជីវកម្មសំរាប់ស្ត្រីនៅក្នុងសហគ្រាស។

## ប្លង់វគ្គសិក្សា

### ជំហានទី១ - ១០នាទី

ណែនាំពីលំហាត់បំផុសគំនិត របៀបគ្រប់គ្រងអាជីវកម្មរបស់អ្នក ដែលជាឧបករណ៍ ដើម្បីត្រួតពិនិត្យតំរូវការ និងលទ្ធភាពផ្សេងៗសំរាប់ការគ្រប់គ្រងអាជីវកម្ម។ គូរដ្យាក្រាមនៅលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ ហើយចែកកាតដែលមាន៤ពណ៌ទៅសិក្ខាកាមគ្រប់គ្នា។

ពន្យល់ថា រង្វង់នៅចំកណ្ដាល តំណាងអោយអាជីវកម្ម (មានស្រាប់ ឬថ្មី) របស់សិក្ខាកាមម្នាក់ៗ។ ពន្យល់ថាពណ៌នីមួយៗតំណាងអោយសំណួរខុសៗគ្នា :

១. (កាតពណ៌លឿង): តើខ្ញុំមានភារកិច្ចចំបងអ្វីខ្លះ នៅក្នុងអាជីវកម្ម?

២. (កាតពណ៌ខៀវ): តើតួនាទីអ្វីខ្លះ ដែលគ្រួសាររបស់ខ្ញុំ ឬក្រុមរបស់ខ្ញុំអាចដើរតួក្នុងការប្រតិបត្តិអាជីវកម្មរបស់ខ្ញុំបាន?

៣. (កាតពណ៌ក្រហម): តើអ្វីទៅជាគុណសម្បត្តិនៃការធ្វើការងារជាលក្ខណៈបុគ្គល គ្រួសារ ឬជាក្រុម?

៤. (កាតពណ៌បៃតង): តើអ្វីទៅជាគុណវិបត្តិនៃការធ្វើការងារជាលក្ខណៈបុគ្គល គ្រួសារ ឬជាក្រុម?

ធ្វើទៅតាមសំណួរទាំង៤មួយជំហានម្ដងៗ។ សុំអោយសិក្ខាកាមសរសេរពីគំនិត និងយោបល់របស់គេ នៅលើក្រដាសពណ៌ទាំងនោះ។ ប្រមូលក្រដាសមកវិញ ធ្វើការពិភាក្សា និងយកទៅបិទនៅលើក្រដាសផ្ទាំងធំ ឬនៅលើក្ដារខៀន ដូចតទៅ :



ពិភាក្សានិងសង្ខេបគំនិតទាំងអស់នៅលើក្រដាសតូច កំណត់គំនិតទាំងនេះថាជាឱកាស និងជាការប្រឈមមុខដែលបុរស ស្ត្រីម្នាក់ៗជួបប្រទះ នៅពេលពិនិត្យមើលសមត្ថភាពផ្ទាល់ខ្លួនរបស់គាត់ក្នុងការគ្រប់គ្រងអាជីវកម្មជាលក្ខណៈបុគ្គល ឬគ្រប់គ្រងរួមគ្នាជាមួយគ្រួសារ ឬក្រុម។ ពិនិត្យមើលថាតើមានភាពស្រដៀងគ្នា ឬខុសគ្នារវាងសិក្ខាកាមទាំងអស់ ហើយធ្វើការសន្និដ្ឋានទៅលើគុណសម្បត្តិ និងគុណវិបត្តិរបស់ទស្សនៈទាំងនោះ នៅក្នុងប្រភេទអាជីវកម្មនីមួយៗ។ ពិនិត្យមើលទំនាក់ទំនងនៅក្នុងអាជីវកម្មៈ អ្នកណាធ្វើអ្វីខ្លះ? អ្នកណាជាអ្នកសំរេចចិត្ត? តើប្រាក់ចំណូលដែលរកបានត្រូវបានបែងចែកយ៉ាងណា? តើមានភាពខុសគ្នាដែរឬទេ រវាងតួនាទីរបស់បុរស និងស្ត្រី និងសមាជិកទាំងក្មេងទាំងចាស់នៅក្នុងអាជីវកម្ម?

### ជំហានទី២ - ៣០នាទី

សុំអោយសិក្ខាកាមជ្រើសរើសសកម្មភាពអាជីវកម្មរបស់គេ (អាជីវកម្មកំពុងមានស្រាប់ និងអាជីវកម្មថ្មី)ៈ តើអាជីវកម្មរបស់អ្នក ៈ

- ជាលក្ខណៈបុគ្គល ប្រតិបត្តិ និងគ្រប់គ្រងភាគច្រើនដោយខ្លួនអ្នកម្នាក់ឯងឬ?
- ជាលក្ខណៈគ្រួសារ តើអ្នកធ្វើការជាមួយសមាជិកគ្រួសារនៅឯណា?
- ជាលក្ខណៈក្រុម តើអ្នកធ្វើការជាមួយសមាជិកក្រុមនៅឯណា ឧទាហរណ៍ ស្ត្រីដទៃទៀត ឬគ្រួសារនៅក្នុងភូមិរបស់អ្នក ឬអ្នកជិតខាង?
- ការផ្សំបញ្ចូលគ្នាលក្ខណៈខាងលើនេះ ទាំងអស់?

ណែនាំនិងពន្យល់អំពី ‘‘តារាងម៉ាទ្រីកផែនការសកម្មភាពជំនួយ និងរារាំង’’ (ជំនួយការបណ្តុះបណ្តាលទី៧៥)។ តារាងម៉ាទ្រីកនេះ គឺជាឧបករណ៍មួយ ដើម្បីអោយសិក្ខាកាមចេះកំណត់មនុស្ស និងធនធានដែលគេគិតថា អាចជួយគេបាន និងមនុស្ស និងធនធាន ដែលអាចរារាំងពួកគេក្នុងការអនុវត្តន៍អាជីវកម្ម(គំនិត)របស់គេ។ ចែកសិក្ខាកាមជាបួនក្រុមអាស្រ័យទៅតាមសកម្មភាពអាជីវកម្មរបស់គេ។ ចែកក្រដាសផ្ទាំងធំដែលមាន ‘‘តារាងម៉ាទ្រីកផែនការសកម្មភាពជំនួយ និងរារាំង’’ ទៅអោយក្រុមនីមួយៗ ហើយសុំអោយពួកគេបំពេញគំនិត បទពិសោធន៍ និងផែនការរបស់គេនៅក្នុងតារាងនោះ។

នៅពេលសិក្ខាកាមបានកត់ត្រាអង្គធាតុទាំងនេះ សុំអោយពួកគេគូសបន្ទាត់ពីក្រោមកត្តាសំខាន់ៗបំផុតៈ កត្តាជំនួយសំគាល់ដោយពណ៌មួយ និងកត្តារារាំងសំគាល់ដោយពណ៌មួយទៀត។ មនុស្សដដែលអាចបង្ហាញទាំងកត្តាជំនួយ ទាំងកត្តារារាំង ឧទាហរណ៍ សមាជិកគ្រួសារដែលមានអំណាចអាចជួយការងារបានច្រើន តែក៏អាចជាការគំរាមគំហែងផងដែរ ប្រសិនបើគាត់ ឬនាងមិនយល់ស្របតាមគំនិតដែលបានលើកឡើង។

## ជំហានទី៣ - ២០នាទី

ពិភាក្សាសង្ខេបនូវលទ្ធផលរបស់ក្រុមការងារនៅក្នុងក្រុមធំ។ នៅក្នុងការសន្និដ្ឋាន បង្ហាញពីភាពដូចគ្នានៅក្នុងកត្តាជំនួយ និងកត្តារារាំង ក្នុងចំណោមប្រភេទអាជីវកម្មខុសៗគ្នា។ ត្រូវពិភាក្សាផងដែរអំពីភាពខុសគ្នានៅក្នុងប្រភេទអាជីវកម្មនីមួយៗ: តើប្រភេទអាជីវកម្មនីមួយៗមានកត្តាអំណោយផល/ឱកាស និងការប្រឈមមុខអ្វីខ្លះ? សុំអោយសិក្ខាកាមពិភាក្សាអំពីរបៀបចូលប្រឡូកនិងទាញប្រយោជន៍ពីការគាំទ្ររបស់មនុស្សដែលជា ‘ជំនួយ’ សំខាន់ៗ និងធនធានដែលត្រូវការ និងពីរបៀបរកព័ត៌មានទាំងឡាយដែលអាច ‘រារាំង’ នៅក្នុងអាជីវកម្មរបស់គេ។

ដើម្បីជាការជួយណែនាំអ្នកបណ្តុះបណ្តាលៈ កត្តាជំនួយ និងកត្តារារាំងមួយចំនួន មានដូចជា :

| ប្រភេទអាជីវកម្ម | កត្តាជំនួយ | កត្តារារាំង |
|---|---|---|
| អាជីវកម្មជាលក្ខណៈបុគ្គល | ខ្ញុំអាចគ្រប់គ្រងអាជីវកម្មដោយខ្លួនឯងបាន<br>ខ្ញុំអាចធ្វើការសំរេចចិត្តបានលឿន<br>ខ្ញុំមានសេរីភាពធ្វើអ្វីដែលខ្ញុំចង់ធ្វើ | ខ្ញុំមានការលំបាកក្នុងការដោះស្រាយការងារៈ ចាត់ចែង និងគ្រប់គ្រង និងធ្វើផលិតផល ឬផ្តល់សេវាកម្មនៅក្នុងពេលតែមួយ |
| អាជីវកម្មជាលក្ខណៈគ្រួសារ ឬជាក្រុម | ខ្ញុំអាចទុកចិត្តគ្រួសាររបស់ខ្ញុំ/ដៃគូអាជីវកម្ម នៅពេលយើងធ្វើការសំរេចចិត្តពិបាកៗ<br>មានកំលាំងច្រើន<br>មានមនុស្សច្រើន អាចធ្វើបានច្រើន<br>គ្រប់ៗគ្នាអាចចូលរួមវិភាគ ដើម្បីអាជីវកម្ម | គ្រួសាររបស់ខ្ញុំនិងដៃគូអាជីវកម្មមិនបានយកចិត្តទុកដាក់មកលើរូបខ្ញុំ ពីព្រោះខ្ញុំជាស្រី<br>ការសំរេចចិត្តលើអ្វីមួយ ប្រើពេលយូរ ហើយជាញឹកញាប់មិនត្រូវបានព្រមព្រៀងគ្នាឡើយ<br>ខ្ញុំមិនអាចធ្វើការសំរេចចិត្តណាមួយបានឡើយ ពីព្រោះគ្រួសារ និងដៃគូរបស់ខ្ញុំយល់ឃើញថា ខ្ញុំនៅក្មេងពេក |

ជំនួយការបណ្តុះបណ្តាលទី៧៥

# តារាងម៉ាទ្រីកផែនការសកម្មភាព: កត្តាជំនួយ និង កត្តារារាំង

## Help & Hinder Action Planning Matrix

ប្រភេទអាជីវកម្ម : .........................................................................................

| អ្នកណា? | ជាមួយអ្នកណា? | អ្វី? | នៅពេលណា? | ជំនួយ (+) | រាំង (-) |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

# លំហាត់ទី២៦ : អាជីវកម្មជាលក្ខណៈគ្រួសារៈ ការចែករំលែកការងារ ការធ្វើសេចក្តីសំរេចចិត្ត និងប្រាក់ចំណូល

## គោលដៅ

ដើម្បីស្វែងយល់ពីសារៈសំខាន់នៃការសំរេចចិត្ត ស្តីពី របៀបបែងចែក និងចែករំលែកការងារ ការធ្វើសេចក្តីសំរេចចិត្ត និងប្រាក់ចំណូលនៅក្នុងការបង្កើតអាជីវកម្មជាលក្ខណៈគ្រួសារ ។

## រយៈពេលៈ ៩0នាទី

## ការរៀបចំបន្ទប់រៀន

- រៀបចំកន្លែងអង្គុយរៀនជាងរាង អក្សរ U និងមានកន្លែងទំនេរសំរាប់ក្រុមតូច ( ជំហានទី១
- រៀបចំកៅអីជារង្វង់នៅចំកណ្តាលកន្លែងអង្គុយជារាងអក្សរ U ( ជំហានទី២)

## ឯកសារមេរៀន

- ករណីសិក្សាៈ អាជីវកម្មរបស់គ្រួសារ អារ៉ៃ
- តារាងចំលើយសំរាប់ករណីសិក្សាៈ អាជីវកម្មរបស់គ្រួសារ អារ៉ៃ
- ការគ្រប់គ្រងអាជីវកម្មជាលក្ខណៈគ្រួសារ ឬជាក្រុមៈ បញ្ជីសារពើភ័ណ្ឌ ( ជំរើសជំហានទី៤)

## ការត្រៀមរៀបចំ

អ្នកបណ្តុះបណ្តាល ឬអ្នកសំរបសំរួលត្រូវអានករណីសិក្សា មុនពេលវគ្គចាប់ផ្តើម ។ ប្រសិនបើសិក្ខាកាមមិនចេះអានអក្សរ ជ្រើសរើសអ្នកបណ្តុះបណ្តាលម្នាក់ ឬសិក្ខាកាមដែលចេះអក្សរ ឬដែលមានបទពិសោធន៍ធ្វើជាអ្នកដឹកនាំក្រុមនីមួយៗ ដោយពិនិត្យមើលករណីសិក្សាកំឡុងពេលនៃការត្រៀមរៀបចំការសំដែងតួ ។

## ឬខ់ទគ្គសិក្សា

### ជំហានទី១ - ៣០នាទី

ណែនាំពីករណីសិក្សា: អាជីវកម្មរបស់ក្រុមគ្រួសារអារ៉ៃ (ជំនួយការបណ្តុះបណ្តាលទី៧៦)។ ដំបូងត្រូវនិទានរឿងនេះអោយក្រុមធំស្តាប់។ បន្ទាប់មកចែកទៅអោយសិក្ខាកាមគ្រប់គ្នា ប្រសិនបើសិក្ខាកាមអាចអាន ឬផ្តល់អោយក្រុមអ្នកសំរបសំរួលម្នាក់មួយច្បាប់សំរាប់ប្រើនៅក្នុងក្រុមតូច។ តួនាទីរបស់អ្នកសំរបសំរួលគឺត្រូវអាន មិនមែនណែនាំឬក៏បង្ហាត់បង្ហាញទៅក្រុមទេ។

ចែកសិក្ខាកាមជាក្រុមដែលមួយក្រុមៗមានសមាជិកយ៉ាងតិច៥នាក់ ហើយសុំអោយពួកគេរៀបចំការសំដែងតួមួយដើម្បីជួយគ្រួសារអារ៉ៃ។ អ្នកសំដែងនៅក្នុងសាច់រឿងគឺមានសមាជិកគ្រួសារចំនួន៣នាក់ដែលធ្វើការនៅក្នុងអាជីកម្មជាលក្ខណៈគ្រួសារនេះ គឺមានឈ្មោះ ណូយ ស៊ូនី និងប៉ុង និងមានអ្នកប្រឹក្សាយោបល់ពីរនាក់ទៀតមកពីអង្គការមួយដែលធ្លាប់បានជួយពួកគេពីមុន។ សុំអោយក្រុមជ្រើសរើសសំនួរមួយឬច្រើន ដើម្បីដោះស្រាយបញ្ហានៅក្នុងឆាកសំដែងតួនេះ សំនួរមានដូចតទៅ:

- តើ ណូយ ស៊ូនី និងប៉ុងមានភារកិច្ច និងការទទួលខុសត្រូវអ្វីខ្លះ?
- តើមានជំនាញសំខាន់ៗ និងអាកប្បកិរិយាអ្វីខ្លះ ដែលត្រូវការសំរាប់ភារកិច្ចនីមួយៗ?
- តើពួកគេបែងចែកការងារយ៉ាងដូចម្តេច ហើយអ្នកណាជាអ្នកធ្វើការសំរេចចិត្ត?
- តើអ្នកមានដំបូន្មានអ្វីខ្លះ ដើម្បីអោយគ្រួសារនេះចេះគ្រប់គ្រងអាជីវកម្មរបស់គេអោយបានប្រសើរជាងមុន ដូចជា បន្ទុកការងារ និងការធ្វើសេចក្តីសំរេចចិត្ត?
- ក្នុងមួយខែណូយបានដកប្រាក់ចំណូលពីអាជីវកម្មចំនួន១០០ឯកតា (គិតជារូបិយប័ណ្ណក្នុងស្រុក ឬតាមចំនួនជាក់ស្តែង)យកទៅទុកដោយឡែក សំរាប់ធ្វើជាសោហ៊ុយពលកម្មរបស់សមាជិកគ្រួសារ តើអ្នកណាខ្លះគួរទទួលលុយនេះ តើប្រាក់ចំណូលនេះចែកជាភាគហ៊ុនអ្វីខ្លះ?

**ជំហានទី២ - ៤០នាទី**

ក្រុមនីមួយៗមានពេលយ៉ាងច្រើន៥នាទីសំរាប់ការឡើងសំដែងតួនេះ។

**ជំហានទី៣ - ២០នាទី**

ពិភាក្សាសំនួរនៅក្នុងក្រុមធំ ហើយទាញរកចំនុចដូចគ្នា/ស្រដៀងគ្នា និងចំនុចខុសគ្នានៅក្នុងលទ្ធផលនៃការសំដែងតួ។ ក្រុមអ្នកបណ្តុះបណ្តាលអាចប្រើតារាងចំលើយសំរាប់ករណីសិក្សានេះ (ជំនួយការបណ្តុះបណ្តាលទី៧៧) ដើម្បីជាការណែនាំដល់ការពិភាក្សានេះ។ សរសេរមតិយោបល់ទាំងអស់នៅលើក្រដាសផ្ទាំងធំ ដូច្នេះសិក្ខាកាមទាំងអស់អាចតាមដានការពិភាក្សាដោយងាយស្រួល។

**សរុបសេចក្តីដោយបង្ហាញអំពី :**

- វាជារឿងសំខាន់នៅក្នុងអាជីវកម្មជាលក្ខណៈគ្រួសារ ដែលត្រូវបែងចែកអោយច្បាស់ ថាតើអ្នកណាធ្វើអ្វីខ្លះ? តើអ្នកសំរេចចិត្តលើអ្វីខ្លះ? និង អ្នកណារក(ធ្វើរបរ) អ្វីខ្លះ?
- នៅក្នុងសង្គមជាច្រើន ស្ត្រីធ្វើស្ទើរតែគ្រប់ការងារទាំងអស់ ប៉ុន្តែពួកគេមិនសូវបានចូលរួមក្នុងការធ្វើសេចក្តីសំរេចចិត្តឡើយ។ ជារឿយៗ ពួកគេរកលុយបានតិចជាងបុរស ដែលធ្វើការងារប្រភេទដូចគ្នា ឬស្រដៀងគ្នា។
- ជារឿយៗ សមាជិកគ្រួសារដែលមានវ័យក្មេង តែងតែជួបបញ្ហាដែលឪពុកម្តាយរបស់គេ ឬបងៗរបស់គេចង់សំរេចចិត្តជំនួសពួកគេ ថាអ្វីទៅជារឿងល្អសំរាប់ប្អូនៗ ទោះបីជាក្មេងៗទាំងនោះមានដំណោះស្រាយសំរាប់ជីវិត និងបទពិសោធន៍ក្នុងអាជីវកម្មក៏ដោយ។
- ប្រសិនបើការបែងចែកការងារ ការធ្វើសេចក្តីសំរេចចិត្ត និងប្រាក់ចំណូលមានភាពមិនស្មើគ្នា ឬមានភាពអយុត្តិធម៌នៅក្នុងគ្រួសារ មុន ឬក្រោយវាគង់តែមានបញ្ហាជាមិនខាន។
- ការនេះវាស្រេចតែលើគ្រួសារនីមួយៗ ដើម្បីធ្វើអោយមានតុល្យភាពល្អនៅក្នុងការចែករំលែកការងារ ការធ្វើសេចក្តីសំរេច និងប្រាក់ចំណូល ហើយវាជារឿងសំខាន់ដើម្បីអោយគ្រប់ៗគ្នាបានដឹងថា ការមានអាយុ និងបទពិសោធន៍ខុសគ្នានឹងនាំមកនូវជំនាញចំរុះចំពោះអាជីវកម្ម។

**ជំហានទី៤ - ៥នាទី (ជំរើស)**

លំហាត់ធ្វើនៅផ្ទះ-ចែកឯកសារស្តីពីការគ្រប់គ្រងអាជីវកម្មជាលក្ខណៈគ្រួសារ ឬជាក្រុមៈ បញ្ជីសារពើភ័ណ្ឌ (ជំនួយការបណ្តុះបណ្តាលទី៧៨)។ សិក្ខាកាមត្រូវបានគេស្នើអោយបំពេញនៅក្នុងតារាងបញ្ជីសារពើភ័ណ្ឌ ដើម្បីអោយយល់ដឹងកាន់តែច្រើន អំពីរបៀបគ្រប់គ្រងអាជីវកម្មជាលក្ខណៈគ្រួសារ ឬជាក្រុម។ កិច្ចការនេះអាចធ្វើជាបុគ្គលក៏បានដែរ នៅចុងបញ្ចប់នៃថ្ងៃបណ្តុះបណ្តាល។

អាស្រ័យលើតំរូវការ និងចំណាប់អារម្មណ៍របស់សិក្ខាកាម សិក្ខាកាមខ្លះអាចចែករំលែកបញ្ជីសារពើភ័ណ្ឌរបស់គាត់នៅក្នុងក្រុមធំ នៅថ្ងៃបន្ទាប់ និង/ឬអ្នកបណ្តុះបណ្តាលអាចផ្តល់យោបល់ដល់ពួកគេអំពីតំរូវការជាមូលដ្ឋានរបស់បុគ្គល។

ជំនួយការបណ្តុះបណ្តាលទី៧៦

# ករណីសិក្សា : អាជីវកម្មរបស់គ្រួសារអារ៉ៃ

## Case Study: The Business of Family Arai

១. កាលពី៣០ឆ្នាំមុន អ្នកស្រីណ្យេយនិងប្តីរបស់គាត់គឺលោកប៉ៃបានបង្កើតហាងលក់ឥវ៉ាន់ និងហាងជួសជុលតូចមួយនៅពីមុខផ្ទះរបស់គាត់ ដែលនៅចំកណ្តាលភូមិជិតវត្តនិងសាលារៀន នៅក្នុងតំបន់ជនបទមួយ ។ លោកប៉ៃគឺជានាយកអាជីវកម្ម ហើយគាត់ធ្វើផ្នែកជួសជុល ។ រីឯអ្នកស្រីណ្យេយជាអ្នកមើលថែទាំហាងលក់ឥវ៉ាន់ ។ ពួកគេទាំងពីរនាក់ប្រឹងប្រែងធ្វើការងារណាស់ និងបានប្រើប្រាស់លុយចំណេញ ដើម្បីធ្វើអោយអាជីវកម្មកាន់តែល្អប្រសើរឡើង ។ តែអ្វីដែលគួរអោយសោកស្តាយនៅក្នុងជីវិតនោះ គឺថា ពួកគេទាំងពីរនាក់ពុំមានកូនឡើយ ។

២. ច្រើនឆ្នាំក្រោយមក ភូមិដ្ឋាននោះមានការអភិវឌ្ឍន៏រីកចំរើនឡើង ។ អ្នកស្រីណ្យេយបានបន្ថែមផលិតផលកាន់តែច្រើនមុខទៀតលក់នៅក្នុងហាង ដូចជា បង្អែម និងស្ករគ្រាប់ដែលធ្វើពីផ្លែឈើដាំនៅក្នុងសួនជុំវិញផ្ទះរបស់គាត់ ។ នៅខណ:ដែលមានតំរូវការច្រើនចំពោះផលិតផលទាំងនេះ ហើយជួនពេលដែលមានស្ត្រីក្នុងភូមិជាច្រើននាក់ចង់រកប្រាក់ចំណូលខ្លះ១ផងនោះ គាត់ក៏ចាប់ផ្តើមទិញម្ស៉ៅធ្វើនំពីពួកគេ ហើយលក់វានៅហាងគាត់ ។ ចំណែកឯហាងជួសជុលវិញក៏មានដំណើរការល្អដែរ ។ ប្រជាជនក្នុងភូមិបានចាប់ផ្តើមប្រើប្រាស់ម៉ាស៊ីនសំរាប់ការងារស្រែចំការ និងអ្នកខ្លះទៀតបានទិញកង់ ម៉ូតូ និងរថយន្តដឹកទំនិញសំរាប់ដឹកជញ្ជូនផលិតផលកសិកម្មទៅទីផ្សារដែលស្ថិតនៅក្នុងទីប្រជុំមួយដែលមានចំងាយ២០គ.មពីភូមិ ។ មានមនុស្សជាច្រើនបានមករកលោកប៉ៃអោយជួសជុលឧបករណ៏ទាំងនោះ ដោយសារតែពួកគេ ទិញរបស់ជជុះ(របស់ជុំនំ) មកប្រើ ហេតុនេះជាញឹកញាប់គ្រឿងម៉ាស៊ីន កង់ ម៉ូតូ ឡានរបស់ពួកគេ តែងតែឧស្សាហ៏ខូច ។

ជំនួយការបណ្ដុះបណ្ដាលទី៧៦

៣. អ្នកស្រីណួយ និងលោកប៉ៃសប្បាយចិត្តណាស់ដែលអាជីវកម្មរបស់គាត់កំពុងដំណើរការបានល្អមែនទែន។ ច្រើនឆ្នាំក្រោយមក លោកប៉ៃបានក្លាយជាមនុស្សមានអារម្មណ៍ឆាប់ខឹង មួរម៉ៅ នៅពេលដែលសុខភាពរបស់គាត់ចាប់ផ្ដើមធ្លាក់ចុះ។ ដូច្នេះ ជួនកាលពួកគេបានទាស់ទែងគ្នាអំពីការគ្រប់គ្រងហាង។ អ្នកស្រីណួយសប្បាយចិត្ត ហើយបានសំរេចចិត្តប្រគល់ហាងជួសជុលអោយទៅប្ដីរបស់គាត់ ប៉ុន្តែគាត់នៅគ្រប់គ្រងហាងលក់ដូរឥវ៉ាន់ និងធ្វើកិច្ចការគ្រប់សព្វទាំង ការលក់ចេញ ទិញចូល គាត់បានចាត់ទុកថា គាត់មានសមត្ថភាពក្នុងការធ្វើសេចក្ដីសំរេចចិត្តអំពីការគ្រប់គ្រងអាជីវកម្មមួយផ្នែកនេះបានល្អ។ ទោះបីយ៉ាងណាក៏ដោយ កាលពីសម័យមុន មនុស្សនៅក្នុងភូមិនៅតែជឿថាបុរសគឺជាអ្នកដឹកនាំដ៏ល្អ ហើយលោកប៉ៃតែងតែយកអំណះអំណាងនេះមកប្រើនៅពេលដែលគាត់មិនយល់ព្រមតាម។ ជាធម្មតា អ្នកស្រីណួយបានផ្ដល់ការសំរេចចិត្តនេះអោយទៅលោកប៉ៃ ពីព្រោះគាត់ស្រលាញ់ប្ដី ទោះបីជាគាត់មិនយល់ព្រមតាមក៏ដោយ។ ហើយឆ្នាំក្រោយមក លោកប៉ៃបានចាប់ផ្ដើមជឿជាក់កាន់តែច្រើនឡើងទៅលើការវិនិច្ឆ័យត្រឹមត្រូវរបស់ប្រពន្ធគាត់ ទោះបីជាគាត់មិនដែលបានសរសើរដោយត្រង់ នៅចំពោះមុខក៏ដោយ។

៤. ដោយសារពួកគាត់គ្មានកូន ហើយពួកគាត់ពិតជាត្រូវការអោយមានអ្នកជួយក្នុងដំណើរការអាជីវកម្មនេះ ពួកគាត់បានសុំអោយក្មួយស្រីឈ្មោះស៊ូនី និងបងប្រុសរបស់នាងឈ្មោះប៉ុងអោយជួយ។ ស៊ូនីបានរៀនចប់ថ្នាក់មធ្យមសិក្សា ហើយបានរៀនកំព្យូទ័រ និងគណនេយ្យទៀតផង ប៉ុន្តែនាងមិនទាន់រកបានការងារធ្វើនៅឡើយទេ។ នាងសប្បាយចិត្តណាស់ដែលមានឱកាសប្រើជំនាញនេះមកជួយធ្វើការឪពុកមា និងម្ដាយមីងរបស់នាង។ ចំនែកប៉ុងធ្លាប់បានរៀននៅសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈ។ គាត់ធ្លាប់ធ្វើការជាកម្មករនៅក្នុងទីក្រុងពីរបីឆ្នាំដែរ។ គាត់សប្បាយចិត្តណាស់ ដែលបានវិលត្រឡប់មកភូមិវិញ នៅពេលដែលមាមីងរបស់គាត់ បានសុំអោយគាត់ជួយការងារក្នុងហាងជួសជុល។ ស៊ូនី និងប៉ុងបានធ្វើការក្រៅម៉ោងអស់រយៈពេល២ឆ្នាំ ហើយ ពូប៉ៃ និងអ្នកស្រីណួយពិតជាសប្បាយចិត្តមែនដោយមានពួកគេនៅជិត និងជួយការងារអាជីវកម្ម ពីព្រោះគាត់មានការងារច្រើនណាស់ ដូច្នេះពួកគេក៏បានធ្វើការពេញម៉ោងអស់រយៈពេលបីឆ្នាំកន្លងផុតទៅ។

ជំនួយការបណ្ដុះបណ្ដាលទី៧៦

៥. មួយឆ្នាំមុន លោកប៉ៃក៏បានលាចាកលោកទៅ។ នេះគឺជាក្តីវិន្ធត់មួយចំពោះពួកគេទាំងអស់គ្នា។ ចាប់តាំងពីពេលនោះមក អ្នកស្រីណូយបានធ្វើការទទួលខុសត្រូវក្នុងការធ្វើផែនការ និងការគ្រប់គ្រងអាជីវកម្ម ទាំងហាងលក់ឥវ៉ាន់ ទាំងហាងជួសជុល។ អ្នកស្រីណូយក៏បានទទួលរ៉ាប់រងទាំងការទិញចូល និងលក់ចេញនៅក្នុងភូមិផងដែរ។ គាត់គឺជាអ្នកគ្រប់គ្រងប្រតិបត្តិការ និងទទួលខុសត្រូវក្នុងការរចនាផលិតផល និងការទំនាក់ទំនងជាមួយផលិតករនៅក្នុងស្រុក។

៦. ស៊ូនីចូលចិត្តការងារផ្នែកអាជីវកម្ម។ នាងបានចាប់ផ្តើមទិញផលិតផលសូត្រពីស្ត្រីក្នុងភូមិ ហើយយកទៅលក់នៅក្នុងហាង។ នាងក៏ចូលចិត្តធ្វើដំណើរនិងរៀនសូត្រអ្វីដែលថ្មីដែរ។ នាងបានទៅទីក្រុងកន្លែងដែលនាងបានទៅមើលការតាំងពិព័ណពាណិជ្ជកម្ម។ នាងបានចាប់ផ្តើមធ្វើការកត់ត្រាបញ្ជីអាជីវកម្មនៅក្នុងកំព្យូទ័រ ដើម្បីត្រួតពិនិត្យហិរញ្ញវត្ថុអោយបានល្អ ហើយឥឡូវនេះ នាងធ្វើគ្រប់ការងារគណនេយ្យទាំងអស់។ នេះគឺជាការងារច្រើនណាស់ទោះបីជាមានកំព្យូទ័រក៏ដោយ។ លើសពីនេះទៅទៀត នាងក៏បានចាប់ផ្តើមធ្វើទំនាក់ទំនងជាមួយអតិថិជនថ្មីៗនៅក្នុង ទីក្រុងតាមរយៈអ៊ីម៉ែល និងទូរស័ព្ទ។ អតិថិជនថ្មីទាំងនេះ បានចាប់អារម្មណ៍ជាពិសេសទៅលើវាយនភ័ណ្ឌសូត្រស្អាតៗ ដែលត្បាញដោយស្ត្រីនៅក្នុងភូមិ។ ការលក់ដូរមុខរបរវាយនភ័ណ្ឌទាំងនេះកំពុងតែលក់ដាច់ខ្លាំងណាស់ ស្របពេលដែលស្ត្រីនៅក្នុងភូមិជាច្រើននាក់ចូលចិត្តរកប្រាក់ចំណូលជាមួយនឹងតម្បាញនេះ។ ស៊ូនីគឺជាអ្នកគ្រប់គ្រងផ្នែកទីផ្សារ ដើម្បីធ្វើការទាក់ទងជាមួយអ្នកភូមិខាងក្រៅ។ មនុស្សនៅក្នុងភូមិ សំដែងការកោតសរសើរដល់នាង ហើយនាងត្រូវបានគេស្គាល់ថាជា ‘‘ក្មេងស្រីដ៏ឆ្លាតវៃ’’។ ឥឡូវនេះ ការលក់ និងការទិញផលិតផលវាយនភ័ណ្ឌគឺជាផ្នែកមួយរបស់អាជីវកម្មដែលទទួលបានប្រាក់ចំណេញជាងគេ។ នាងបានព្យាយាមពន្យល់អ្នកស្រីណូយ និងប៉ុងអំពីមុខរបរនេះ ប៉ុន្តែវាហាក់ដូចជាពិបាកសំរាប់អោយពួកគេយល់ដឹង។

ជំនួយការបណ្ដុះបណ្ដាលទី៧៦

៧. ប៉ុងគឺជាអ្នកបច្ចេកទេសពូកែម្នាក់។ គាត់ត្រូវបានគេស្គាល់ថា ជាបុរសដៃមាស ពីព្រោះគាត់តែងតែអាចជួសជុលគ្រប់ឧបករណ៍ទាំងអស់ មិនថាឡើយជារបស់ថ្មី ឬរបស់ចាស់ឡើយ។ អ្នកស្រីណួយទើបតែទិញប្រដាប់ប្រដាជួសជុលថ្មីៗ និងបានកែលំអរោងជាងជួសជុលឡើងវិញ។ ប៉ុងហាក់ដូចជាសប្បាយចិត្តណាស់ជាមួយនឹងការងាររបស់គាត់។ នៅរដូវវស្សាគាត់មានការងារធ្វើជាច្រើន ពីព្រោះនេះ គឺជាពេលដែលគ្រឿងម៉ាស៊ីន កង់ និងរថយន្តឧស្សាហ៍ខូចណាស់។ ចំនែកឯនៅរដូវប្រាំង ការងារមិនសូវជារវល់ទេ ដែលអាចធ្វើអោយគាត់មានពេលទំនេរទៅដើរលេងជាមួយមិត្តភ័ក្តិ។ ទោះបីយ៉ាងណាក៏ដោយ ឥឡូវនេះ ឪពុកមារបស់គាត់បានស្លាប់ទៅហើយ ដូច្នេះគាត់ចង់មានសិទ្ធិនិយាយស្ដីកាន់តែច្រើនឡើងនៅក្នុងអាជីវកម្ម។ ប៉ុងបានដឹងខ្លួនថា គាត់មិនទាន់បានរកលុយអ្វីធំដុំនៅឡើយទេ ដូច្នេះ ជារឿយៗ គាត់បានយកលុយដែលរកបានពីការជួសជុលទុកសំរាប់ខ្លួនគាត់។ គាត់ចង់ចែកចំណែកអោយបានស្មើៗគ្នា ដូចដែលអ្នកស្រីណួយបានកំណត់លុយមួយផ្នែកទុកជាថ្លៃពលកម្មសំរាប់ពួកគេទាំងបីនាក់នាក់។

៨. ក្រោយៗមក ក្រុមគ្រួសារអារ៉ៃបានជួបប្រទះបទពិសោធន៍ពិបាកៗមួយចំនួន។ អ្នកស្រីណួយបានធ្វើអាជីវកម្មដោយខ្លួនគាត់អស់ពេលជាយូរមកហើយ ប៉ុន្តែឥឡូវនេះ អាជីវកម្មបានពង្រីកយ៉ាងច្រើន គាត់មានការពឹងផ្អែកកាន់តែច្រើនឡើងទៅលើសមាជិកគ្រួសារក្មេងៗ ជាពិសេសគឺនាងស៊ូនី។ ទោះបីយ៉ាងណាក៏ដោយ គាត់នៅតែចង់ធ្វើជាអ្នកអារកាត់នៅក្នុងអាជីវកម្មរបស់គាត់ទាំងស្រុង។ នេះមិនមែនតែងតែជាការងាយស្រួលទេ។ រីឯប៉ុងចង់បានអោយមានលុយ និងមានការសំរេចចិត្តច្រើននៅក្នុងអាជីវកម្ម ពីព្រោះ គាត់គឺជាបុរសម្នាក់នៅក្នុងគ្រួសារ ប៉ុន្តែ នៅក្នុងទស្សនៈរបស់អ្នកស្រីណួយ ប៉ុងនៅមិនទាន់មានភាពចាស់ទុំនៅឡើយ។ នៅក្នុងគំនិតរបស់គាត់ស៊ូនីគឺជាខួរក្បាលរបស់អាជីវកម្មគាត់។ ស៊ូនីបានបង្ហាញថា ហាងកំពុងតែដំណើរការល្អណាស់ នាងមានគំនិតថ្មីៗជាច្រើន និងចង់ពង្រីកអាជីវកម្មទៀតផង ប៉ុន្តែអ្នកស្រីណួយចង់សន្សំលុយអោយបានច្រើនជាជាងចំណាយ។ គាត់គិតថាគាត់ចង់អោយលុយពួកគេច្រើនថែមទៀត ប៉ុន្តែត្រូវអោយ

ម្នាក់ៗប៉ុន្មាន។ គាត់នៅតែមន្ទិលថាតើគួរផ្តល់ការទទួលខុសត្រូវថែមទៀតទៅអោយពួកគេ តែវានៅមិនទាន់ច្បាស់ថា តើត្រូវធ្វើរបៀបណា។

៩. អ្នកប្រឹក្សាយោបល់ពីរនាក់មកពីអង្គការអភិវឌ្ឍន៍អាជីវកម្ម ដែលក្រុមគ្រួសារមីងណូយមានការគោរព និងជឿទុកចិត្តនោះ បានមកពិភាក្សាអំពីស្ថានភាពនេះជាមួយពួកគេ។

## ភារកិច្ចសំរាប់ការសំដែងតួ

ជ្រើសរើសសំណួរមួយឬច្រើន ដើម្បីដោះស្រាយការសំដែងតួរបស់អ្នកៈ

- តើ អ្នកស្រីណូយ ស៊ូនី និងប៉ុងមានភារកិច្ចនិងការទទួលខុសត្រូវអ្វីខ្លះ?
- តើមានជំនាញសំខាន់ៗ និងអាកប្បកិរិយាអ្វីខ្លះដែលត្រូវការសំរាប់ភារកិច្ចនីមួយៗ?
- តើពួកគេបែងចែកការងារយ៉ាងដូចម្តេច ហើយអ្នកណាជាអ្នកធ្វើការសំរេចចិត្ត?
- តើអ្នកមានដំបូន្មានអ្វីខ្លះ ដើម្បីអោយគ្រួសារនេះចេះគ្រប់គ្រងអាជីវកម្មរបស់គេអោយបានប្រសើរ ដូចជា បន្ទុកការងារ និងការធ្វើសេចក្តីសំរេចចិត្ត?
- ក្នុងមួយខែអ្នកស្រីណូយបានដកប្រាក់ចំណូលពីអាជីវកម្មចំនួន១០០ឯកតា ទុកដោយឡែក (គិតជា រូបិយប័ណ្ណក្នុងស្រុក)។ តើអ្នកណាខ្លះគួរទទួលចំណែកលុយនេះ តើប្រាក់ចំណូលនេះចែកជាភាគហ៊ុនអ្វីខ្លះ?

ជំនួយការបណ្តុះបណ្តាលទី៧៧

# តារាងចំលើយសំរាប់ករណីសិក្សា : អាជីវកម្មរបស់គ្រួសារអាប៉ែ

| កិច្ចការ | ភារកិច្ច និង ការទទួលខុសត្រូវ | ជំនាញ និងឥរិយាបថ ដែលត្រូវការ | តើអ្នកណាធ្វើអ្វី? តើអ្នកណាធ្វើការសំរេចចិត្ត |
|---|---|---|---|
| ការគ្រប់គ្រងទូទៅ | ការធ្វើផែនការអាជីវកម្ម<br><br>អ្នកគ្រប់គ្រងប្រតិបត្តិការសំរាប់ហាងជួសជុល ហាងលក់ដូរ ការរចនាផលិតផល និងការទំនាក់ទំនងសាធារណៈ | ធ្វើផែនការ ការចាត់តាំង និងមនុស្សជំនាញ ជំនាញបច្ចេកទេសល្អៗ | បន្ទាប់ពីមរណៈភាពរបស់ប៉ៃ ណូយទទួលបន្ទុកការងារគ្រប់យ៉ាង<br><br>ប៉ុងខកចិត្ត ព្រោះគាត់មិនមាន ‘សិទ្ធិនិយាយ’ អ្វីនៅក្នុងការគ្រប់គ្រង និងការសំរេចចិត្ត! រីឯស៊ូនីគិតគូរសំខាន់ពីអនាគតអាជីវកម្ម ពីព្រោះនាងចង់ធ្វើអោយអាជីវកម្មរីកចំរើន និងពោរពេញទៅដោយគំនិតថ្មីៗ |
| ការចុះបញ្ជី/កត់ត្រា | កត់ត្រាគណនី សាច់ប្រាក់ និងបញ្ជីសារពើភ័ណ្ឌរបស់ហាង | ប្រុងប្រយ័ត្ន មានរបៀបរៀបរយ និងស្មោះត្រង់ | ស៊ូនី: ការកត់ត្រាហិរញ្ញវត្ថុ និងជំនាញវាយកំព្យូទ័រ |
| ការរកទីផ្សារ និង ការផ្សព្វផ្សាយលក់ | ធ្វើការស្រាវជ្រាវទីផ្សារ រក្សាទំនាក់ទំនងល្អជាមួយអតិថិជន ទាក់ទាញអតិថិជនថ្មី កំណត់ថ្លៃ និងលើកសំណើវិធានការផ្សព្វផ្សាយលក់ ដឹងពីចំណាយរបស់អាជីវកម្ម | ស្វាហាប់ និងច្នៃប្រឌិត រីករាយជួបជាមួយមនុស្សម្នា និងពូកែទំនាក់ទំនង និងការចរចារ | ណូយធ្វើទាំងការងារលក់ និងទិញនៅក្នុងភូមិ<br><br>រីឯស៊ូនីធ្វើការផ្សព្វផ្សាយពីសង្ខាក់អាជីវកម្មវាយនភ័ណ្ឌ<br><br>ចំណែកប៉ុងទាក់ទងអតិថិជននៅក្នុងហាងជួសជុល |

ជំនួយការបណ្ដុះបណ្ដាលទី៧៧

| | | | |
|---|---|---|---|
| ផលិតកម្ម និងសេវាកម្ម | រៀបចំផលិតកម្ម និង អភិវឌ្ឍផលិតផល ធានាគុណភាពផលិតកម្ម | ត្រួតពិនិត្យគុណភាពទំផ្សេងៗ រចនាវាយនភ័ណ្ឌ និងគុណភាព បង្កើនចំណេះដឹងផ្នែកជួសជុលគ្រឿងយន្ត ខិតខំធ្វើការ ស្គាល់ផលិតផលបានច្បាស់ ការច្នៃប្រឌិត និងការផ្ដោតទៅលើសេវាកម្ម | ប៉ៃៈ ជានាយកក្រុមហ៊ុន ធ្វើការជួសជុល<br>ណូយៈ ធ្វើការលក់ មានគំនិតរកស៊ីច្បាស់លាស់<br>ប៉ុងៈ ជាបុរសមានថ្វីដៃ<br>ស៊ូនីៈ ជាក្មេងស្រីដែលឆ្លាត |
| តើគេបែងចែកសោហ៊ុយកំលាំងពលកម្មដោយរបៀបណាៈ តើអ្នកណារកអ្វី | | ភាពស្មោះត្រង់ | ជំលោះ : ប៉ុង និងណូយមិនយល់ពីអ្វីដែលស៊ូនីធ្វើឡើយ ។ ប៉ុងចង់បានលុយច្រើន មានសិទ្ធិនិយាយនៅក្នុងអាជីវកម្ម រីឯស៊ូនីចង់កែលំអ និងពង្រីកអាជីវកម្ម អោយបានរីកចំរើន និងប្រសើរឡើង ប៉ុន្តែមិនប្រាកដថា ណូយយល់ព្រមឡើយ |

ជំនួយការបណ្តុះបណ្តាលទី៧៨

## ការគ្រប់គ្រងអាជីវកម្មជាលក្ខណៈគ្រួសារ ឬជាក្រុម : បញ្ជីសារពើភ័ណ្ឌ

## Management of Family or Group Business: Inventory

ដើម្បីប្រតិបត្តិការអោយបានរលូន និងបានជោគជ័យ អ្នកត្រូវចាត់ចែងអាជីវកម្មរបស់អ្នកអោយបានល្អ។ អ្នកត្រូវដឹងពីអ្វីដែលត្រូវធ្វើ និងមានលទ្ធភាពធ្វើការជាមួយនឹងមនុស្សដែលយល់ការងារច្បាស់លាស់។

កម្មករម្នាក់ៗនៅក្នុងអាជីវកម្មនឹងមានឥទ្ធិពលទៅលើភាពជោគជ័យ ឬភាពបរាជ័យរបស់អាជីវកម្ម។ ពិចារណាអោយបានប្រុងប្រយ័ត្ននៅពេលអ្នកជ្រើសរើសមនុស្សអោយធ្វើការជាមួយ។ កំណត់ភារកិច្ចពួកគេអោយបានត្រឹមត្រូវ ណែនាំបង្ហាញពួកគេពីរបៀបរបបការងារអាជីវកម្ម ហើយអោយពួកគេមើលពីរបៀបគ្រប់គ្រងសហគ្រាស។

### តើអ្នកណាជាមនុស្សសំខាន់ នៅក្នុងអាជីវកម្មរបស់អ្នក? មនុស្សនៅក្នុងអាជីវកម្មរបស់អ្នកអាចជាៈ

- ខ្លួនអ្នក ម្ចាស់/ថៅកែ ...............................
- ដៃគូសំខាន់របស់អ្នក (ប្តី ប្រពន្ធ កូន) ...............................
- ដៃគូដទៃទៀតនៅក្នុងអាជីវកម្ម ឬនៅក្នុងគ្រួសារ ...............................
- កម្មករ កម្មការិនី ក្រុមផលិតករ ...............................
- អ្នកផ្សេងទៀត (ដៃគូអាជីវកម្ម) ...............................

### អ្នកគឺជាម្ចាស់/ថៅកែ

នៅក្នុងអាជីវកម្មធុនតូច មនុស្សម្នាក់គឺជាអ្នកគ្រប់គ្រង។ នៅក្នុងអាជីវកម្មលក្ខណៈគ្រួសារ មនុស្សម្នាក់ទទួលបន្ទុកដឹកនាំៈ ភរិយា ស្វាមី សាច់ញាតិស្រី ឬប្រុស។ ម្ចាស់/អ្នកគ្រប់គ្រងប្រតិបត្តិភារកិច្ចជាលក្ខណៈបុគ្គល ឬជាលក្ខណៈរួមគ្នាៈ

ជំនួយការបណ្តុះបណ្តាលទី៧៨

- បង្កើតគំនិត គោលបំណង និងផែនការសកម្មភាពដែលមានលទ្ធផល និងទិន្នផលច្បាស់លាស់ ។
- ចាត់ចែងនិងលើកទឹកចិត្តមនុស្សអោយអនុវត្តផែនការសកម្មភាព ។
- ធានាថាផែនការត្រូវបានគេអនុវត្តតាម ធ្វើដូច្នេះគោលបំណង និងទិន្នផលត្រូវតែបានសំរេច ។
- ធ្វើការសំរេចចិត្ត ដូចជា ការវិនិយោគថ្មី ឬកំចីប្រាក់ ។

នៅក្នុងការធ្វើផែនការអាជីវកម្មថ្មី ចូរគិតអំពីជំនាញអាជីវកម្មរបស់អ្នកផ្ទាល់ ។ សំរេចថា តើអ្នកនឹងជ្រើសរើសការគ្រប់គ្រងប្រភេទណា ហើយកិច្ចការណាមួយដែលអ្នកគិតថាមិនមានពេល មិនមានជំនាញ ដើម្បីអនុវត្ត ។ ចូរពិចារណាពីប្រភេទអ្នកគ្រប់គ្រងដែលអ្នកចង់ធ្វើ ហើយកំណត់ជំនាញ និងបទពិសោធន៍ដែលចាំបាច់សំរាប់តំណែងនោះ ។

## អ្នក និងសមាជិកគ្រួសារ ឬសមាជិកក្រុមរបស់អ្នកៈ

អ្នកមិនដែលមានពេល ឬជំនាញធ្វើការងារទាំងអស់នោះទេ ដូច្នេះអ្នកនឹងត្រូវការជំនួយពីគ្រួសាររបស់អ្នក ឬមួយអាចត្រូវការជួលមនុស្សអោយធ្វើការ ។ សហគ្រាសខ្នាតតូចបំផុតអាចមានកម្មករម្នាក់ឬពីរនាក់ធ្វើការពាក់កណ្តាលម៉ោង ។ រីឯសហគ្រាសដទៃទៀតអាចមាននិយោជិតធ្វើការពេញម៉ោង ។

ដើម្បីស្វែងរកកម្មករដែលអ្នកត្រូវការ ចូរពិចារណាជំហានដូចតទៅៈ

### ១. តើមានមនុស្សណាខ្លះនៅក្នុងអាជីវកម្មរបស់អ្នក?

- ខ្លួនអ្នកដែលជាម្ចាស់ ...............................
- និយោជិត/បុគ្គលិក ...............................
- ផលិតករក្នុងស្រុក ...............................
- អ្នកផ្សេងទៀត ...............................

ជំនួយការបណ្តុះបណ្តាលទី៧៨

## ២, តើខ្លួនអ្នកជាម្ចាស់ ជាអ្នកគ្រប់គ្រង និងជានាយកៈ

- បង្កើតគំនិត គោលបំណង និងផែនការសកម្មភាព ……………………
- ចាត់ចែងនិងលើកទឹកចិត្តមនុស្សអោយអនុវត្តផែនការសកម្មភាព ……………………
- ធានាថាផែនការត្រូវបានគេអនុវត្តតាម ដូច្នេះគោលបំណងអាជីវកម្មត្រូវតែបានសំរេច ………

## ៣, តើអ្នកណាមានទេពកោសល្យអ្វីខ្លះ?

- ប្រុងប្រយ័ត្ន ………………………………
- រៀបរយ/ស្អាតបាត ………………………………
- រៀបចំ/ចាត់ចែង ………………………………
- ស្មោះត្រង់ ………………………………
- ស្វាហាប់/រួសរាន់ ………………………………
- មានគំនិតច្នៃប្រឌិត ………………………………
- ងាយស្រួលទាក់ទងជាមួយ ………………………………
- មានការប្រាស្រ័យទាក់ទងច្បាស់លាស់ ………………………………
- ខិតខំធ្វើការ ………………………………
- ការតំរង់ទៅរកសេវាកម្ម ………………………………
- ការចរចារ ………………………………

វាមានសារៈសំខាន់ណាស់ ដែលអ្នកត្រូវសំរេចអោយបានច្បាស់លាស់អំពីភារកិច្ចសំរាប់មនុស្សគ្រប់ៗគ្នានៅក្នុងក្រុម ឬអាជីវកម្មគ្រួសាររបស់អ្នក។ នៅពេលដែលអ្នកដឹងអំពីកិច្ចការអ្វីដែលគេត្រូវធ្វើ ចូរសរសេររៀបរាប់អំពីការងារសំរាប់តំណែងនីមួយៗ។ នៅក្នុងការពិត ការធ្វើអាជីវកម្មជា

លក្ខណៈគ្រួសារ គេកំរឃើញមានការរៀបចំពិពណ៌នាអំពីការងារណាស់ តែនេះគឺជាវិធីខ្លះៗដែលគេអាចយកទៅកែលំអក្នុងការធ្វើការងាររួមគ្នា ដើម្បីអោយមានការឯកភាព និងកត់ត្រាជាលក្ខណៈងាយៗពីភារកិច្ចរបស់ពួកគេ។ ការពិពណ៌នាការងារ កំណត់អំពីការងារដែលត្រូវធ្វើនៅក្នុងផ្នែកណាមួយនៃអាជីវកម្ម។ ការសរសេរពិពណ៌នាអំពីការងារមានគុណប្រយោជន៍ជាច្រើន ដូចជា:

- មនុស្សបានដឹងពិតប្រាកដអំពីអ្វីដែលគេត្រូវធ្វើ។
- ក្នុងឋានៈអ្នកជាអ្នកគ្រប់គ្រងអាជីវកម្ម អ្នកត្រូវមានការវាស់វែងអំពីទិន្នផលការងារ។

ចូរប្រើការពិពណ៌នាការងារនៅពេលណាដែលអ្នកធ្វើការជ្រើសរើសបុគ្គលិក។ វាជាការសំខាន់ក្នុងការជួលបុគ្គលិកដែលមានជំនាញសមស្រប និងមានទឹកចិត្តធ្វើការ។ អ្នកគួរតែសំភាសន៍បុគ្គលិកដែលមានសក្តានុពលទាំងអស់។ មានព័តិមានជាច្រើនដែលអាចទទួលបានពីការសួរសំនួរនៅពេលអ្នកធ្វើសំភាសន៍ :

- តើអ្នកធ្វើការនៅឯណាពីមុន? ..................................
- តើអ្នកធ្វើការងារអ្វីពីមុន? ..................................
- ហេតុអ្វីបានជាអ្នកចង់ធ្វើការនៅក្នុងអាជីវកម្មនេះ? ..................................
- តើអ្នកកំពុងស្វែងរកតំណែងជាអ្វី? ..................................
- តើអ្នកគិតថាអ្វីជាចំនុចខ្លាំង និង ចំនុចខ្សោយរបស់អ្នក? ..................................
- តើអ្នកចំណាយពេលវេលាទំនេររបស់អ្នកយ៉ាងដូចម្តេច? ..................................
- តើនៅពេលទំនេរអ្នកចូលចិត្តធ្វើអ្វី ដើម្បីកំសាន្ត? ..................................
- តើអ្នកចូលចិត្តធ្វើការជាមួយមនុស្សម្នាផ្សេងទៀត ដែរឬទេ? ..................................
- តើអ្នកមានប្រតិកម្មតបតយ៉ាងដូចម្តេចចំពោះមនុស្សដែលមិនរាក់ទាក់? ........................

ចូរអ្នកសួរអោយបានច្រើន ពីព្រោះសំណួរទាំងនោះផ្តល់ព័តិមានអំពីមនុស្សដែលយើងបានសម្ភាសន៍។ បន្ទាប់មក ប្រាប់មនុស្សទាំងអស់ដែលអ្នកបានធ្វើសម្ភាសន៍អំពីលទ្ធផលនៃការដាក់ពាក្យរបស់ពួកគេ។

# លំហាត់ទី២៧ : ដំណើរនៃការជឿជាក់ (ជំរើស)

## គោលដៅ

- ដើម្បីបង្កើតអោយមានការជឿទុកចិត្តនៅក្នុងក្រុម ។
- ដើម្បីចែករំលែកនិងទទួលព័ត៌មានត្រឡប់ និងការគាំទ្របទពិសោធន៍សំរាប់ការរីកចំរើនរបស់អាជីវកម្ម ក៏ដូចជាការរីកចំរើនសំរាប់បុគ្គល ។

**រយៈពេល:** ៣០នាទី

## ការរៀបចំបន្ទប់រៀន:

រៀបចំអោយមានកន្លែងទូលាយបន្តិច ដែលអាចអោយសិក្ខាកាមដើរចុះឡើងបានដោយសេរី ។ លំហាត់នេះអាចធ្វើនៅខាងក្រៅកន្លែងបណ្តុះបណ្តាលក៏បានដែរ ។

**សំភារៈ:** ក្រណាត់១០-២០ផ្ទាំងសំរាប់រុំមុខ/បិទមុខ (១ផ្ទាំងសំរាប់សិក្ខាកាម១គូ)

## កំណត់ចំណាំសំរាប់អ្នកបណ្តុះបណ្តាល

លំហាត់នេះនឹងជួយពង្រឹកស្មារតីសមាជិកក្រុមការងារនៅកំឡុងពេល (និងក្រោយពេល) បណ្តុះបណ្តាល ។

## មួលបទគ្រូសិក្សា

### ជំហានទី១ - ១៥នាទី

ចូរណែនាំអំពីដំណើរនៃការជឿជាក់។ សិក្ខាកាមនឹងបង្កើតជាដៃគូៈ ម្នាក់ជាអ្នកចាប់ផ្តើមនាំផ្លូវ ហើយម្នាក់ទៀតត្រូវបិទមុខ។ នៅពេលដើរជាមួយគ្នា អ្នកនាំផ្លូវត្រូវពន្យល់ពីមជ្ឈដ្ឋានជុំវិញទៅដៃគូរបស់គាត់។ ៥នាទីក្រោយមក សុំអោយដៃគូដូរតួនាទីគ្នាម្តង ដោយអោយអ្នកនាំផ្លូវធ្វើជាអ្នកបិទមុខ ហើយអ្នកបិទមុខលើកមុនធ្វើជាអ្នកនាំផ្លូវវិញ។

### ជំហានទី២ - ១៥នាទី

សួរសិក្ខាកាមថាតើគេមានអារម្មណ៍បែបណានៅពេលដើរដំបូង ហើយក្រោយមកទៀតយ៉ាងម៉េចដែរ (ដូចជា ត្រូវបានគេបិទមុខ ឬត្រូវធ្វើជាអ្នកនាំផ្លូវ និងពន្យល់ប្រាប់គេ)។ សួរពួកគេ តើគេបង្កើតជំនឿទុកចិត្តយ៉ាងដូចម្តេច នៅក្នុងការនាំផ្លូវ ហើយគេបានដកពិសោធន៍ក្នុងការដឹកនាំ និងការទទួលខុសត្រូវយ៉ាងណា នៅពេលនាំផ្លូវអ្នកដទៃ។

គូសបង្ហាញពីសារៈសំខាន់នៃការបង្កើតទំនុកចិត្ត ការជឿជាក់ និងភាពជាអ្នកដឹកនាំទាំងជាលក្ខណៈបុគ្គល ទាំងជាស្ត្រីអាជីវករ។ នេះគឺជាការសំខាន់សំរាប់ក្រោយពេលបណ្តុះបណ្តាល ដែលសិក្ខាកាមនឹងកសាងចំនុចរៀនសូត្រ ចាប់ផ្តើមធ្វើបណ្តាញរួមគ្នា និងធ្វើដំណើរឆ្ពោះទៅរកការរីកចំរើននៅក្នុងអាជីវកម្មរបស់គេផ្ទាល់។

------ចប់មេរៀន ៤.១ ------